ការសម្ភាសន៍របស់បងស្រី ភិន អៀច

កះ អ្នកសម្ភាសន៍ឈ្មោះ គង់ ចាន់ណាក់ ខះ អ្នកដែលត្រូវបានគេសម្ភាសន៍ឈ្មោះ ភិន អៀច

**ការសម្ភាសន៍ជីវប្រវត្តិសង្ខេបរបស់បងស្រី ភិន អៀច**

សង្ខេបៈ បងស្រី ភិនអៀច រស់នៅភូមិច្រឡោង ឃុំដំរិល ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ។ គាត់ជាកូនច្បងគេនៅក្នុងចំណោមបងប្អូនប្រាំនាក់។ គាត់មិនសូវបានរៀនជ្រៅជ្រះទេ ដោយសារគាត់បានទៅតាមឪពុកម្ដាយរបស់គាត់ ទៅរកស៊ីនៅស្រុកលើ។ នៅក្នុងសម័យពលពត គាត់នៅក្មេងចឹងគាត់ត្រូវបានគេចាត់អោយទៅលើកអាចម៍ក្របីនៅតាមផ្ទះ។ ជីវិតរបស់គាត់មានការលំបាកច្រើន ហើយគាត់បានខិតខំរកស៊ីណាស់ តែគាត់បានថា គាត់មិនសូវបានជួបនឹងការមានបាននឹងគេសោះ ទោះបីគាត់ខិតខំរកស៊ីក៏ដោយក៏គាត់នៅតែមានជីវភាពលំបាក។ធ្វើឡើងនៅភូមិច្រឡោង ឃុំដំរិល ស្រុកអូររាំឪ ខេត្តត្បូងឃ្មុំ ធ្វើឡើងនៅថ្ងៃទី១៧ ខែ០៤ ឆ្នាំ២០១៨។

កះ អញ្ចឹងដំបូង សូមជំរាប់សួរបង!

ខះ ចា៎! ជំរាប់សួរ។

កះ ខ្ញុំបាទឈ្មោះ គង់ ចាន់ណាក់ ហើយខ្ញុំមកពីគម្រោងជីវប្រវត្តិផ្ទាល់ខ្លួនរបស់ប្រជាជនកម្ពុជាដែលគម្រោងត្រូវបានធ្វើឡើងដោយសកលវិទ្យាល័យដែលសកលវិទ្យាល័យនោះមានឈ្មោះថា សាកលវិទ្យាល័យ BYU នៅសហរដ្ឋអាមេរិច។ ហើយគម្រោងមួយនឹង គេចង់អោយយើងថែរក្សាជីវប្រវត្តិរបស់ជីដូនជីតារបស់យើង ដើម្បីអោយកូនចៅជំនាន់ក្រោយគេអាចរៀនសូត្រ។ ហើយសំរាប់ការសំភាសន៍នេះយើងធ្វើឡើងនៅថ្ងៃទី ១៧ ខែ០៤ ឆ្នាំ២០១៨ ហើយសំរាប់ការសំភាសន៍នេះយើងនឹងថតជាសំលេង និងថតរូបភាពរបស់បងស្រី ហើយយើងនឹងផ្ញើរទៅកាន់សាកលវិទ្យាល័យ ដើម្បីពួកគាត់អាចយកទៅដាក់លើ Website របស់សាកលវិទ្យាល័យ។ អញ្ចឹង តើបងស្រីអាចអនុញ្ញាត្តិអោយពួកយើងយករូបថតនិងសំលេងរបស់បងស្រីទៅដាក់លើ Website របស់សកលវិទ្យាល័យបានទេ បងស្រី?

ខះ យកទៅដាក់អី ដាក់ទៅមានថាអី។

កះ អញ្ចឹង! អរគុណបងដែរអនុញ្ញាត្តិអោយយើងសំភាសន៍ពីបង។ អញ្ចឹងពីដំបូងសុំសួរបង តើបងស្រីមានឈ្មោះពេញអ្វីដែរ?

ខះ ខ្ញុំឈ្មោះ ភិន អៀច។

កះ ភិន អៀច! ហើយអញ្ចឹងបង តើបងមានឈ្មោះហៅក្រៅទេ?

ខះ ពេលទៅនៅឆ្ងាយ ភាគច្រើនគេហៅ អៀន។

កៈ អូ! អញ្ចឹងភាគច្រើនអ្នកនៅខាងក្រៅគេហៅបងថា អៀន។ ហ្នឹងហើយ អញ្ចឹងកាលនៅក្មេងៗវិញ គេហៅឈ្មោះបងស្រីថាម៉េចវិញ?

ខៈ កាលពីក្មេងវិញគេហៅឈ្មោះដើម អៀច។

កៈ អៀច ចឹងទៅបងស្រី។ ហ្នឹងហើយ សំរាប់បងស្រី សព្វថ្ងៃនេះបងស្រីមានអាយុប៉ុន្មានហើយ?

ខៈ ខ្ញុំអាយុ សែសិបប្រាំបី សែសិបប្រាំបួនហើយ។

កៈ សែសិបប្រាំបី សែសិបប្រាំបួនហើយ?

ខៈ សែសិបប្រាំបួនហើយ។

កៈ ហើយអញ្ចឹង បងស្រីនៅចាំថា បងកើតនៅថ្ងៃណា ខែណា ឆ្នាំណាទេបងស្រី?

ខៈ អត់នៅចាំទេប្អូនអើយ។

កៈ ហើយចុះបងស្រីមាននៅចាំឆ្នាំទេ?

ខៈ អត់ចាំទេ។

កៈ អញ្ចឹង តើបងស្រីបានកើតមុនអាពត ឬក្រោយអាពតដែរ?

ខៈ ខ្ញុំកើតមុនអាពត កាលនៅអាពតនឹងយើងទើបដើរលើកអាចម៌ក្របីតាមផ្ទះរបស់គេ មិនទាន់ដឹង ថាយើងឆ្នាំអី យើងអាយុប៉ុន្មានអីប៉ុន្មានទេ នៅឡេឡឺនៅឡើយទេ។

កៈ អញ្ចឹងហ៎បង មិនទាន់ដឹង។ អញ្ចឹងបងប្រហែលជាកើតនៅក្នុងឆ្នាំមួយពាន់ប្រាំបួនរយហុកសិប ប្រាំបួន ព្រោះឆ្នាំនេះបងអាយុសែសិបប្រាំបួនឆ្នាំហើយ។

ខៈ មិនចាំទេ ព្រោះអីកាលនឹងនៅមិនទាន់ដឹងអីទេ។

កៈ ហើយអញ្ចឹង តើបងមាននៅចាំថា បងស្រីបានកើតនៅឆ្នាំខ្មែឆ្នាំអីទេបង?

ខៈ មិនចាំទេ ព្រោះអីនៅក្មេងពេក។

កៈ អូ! មិនចាំទេព្រោះនៅតូចពេកន៎បង។ ហើយអញ្ចឹង សំរាប់បង
តើបងកើតនៅកន្លែងណាដែរបងស្រី?

ខៈ ខ្ញុំកើតនៅភូមិយៀក។ ភូមិយៀកយើងផ្លូវទៅចក។

កៈ ហើយអញ្ចឹង បងមាននៅចាំឈ្មោះភូមិ ឃុំ ស្រុក ខេត្តទេ បងស្រី?

ខៈ ភូមិយៀក ឃុំដំរិល ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ។

កៈ ហើយអញ្ចឹង សំរាប់បងស្រី មានបងប្អូនប៉ុន្មាននាក់ដែរ បងស្រី?

ខ៖ ខ្ញុំមានបងប្អូនប្រាំនាក់។

ក៖ តើបងប្អូនរបស់បងស្រីមានស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ខ៖ បងប្អូនរបស់ខ្ញុំមានស្រីបួនប្រុសតែមួយទេ។

ក៖ ស្រីបួនប្រុសមួយ។ ហើយអញ្ចឹងបងស្រីជាកូនទីប៉ុន្មានដែរ បងស្រី?

ខ៖ ខ្ញុំជាកូនច្បងគេ។

ក៖ អញ្ចឹង បងស្រីអាចជួយរៀបរាប់ឈ្មោះរបស់បងប្អូនរបស់បងស្រីទាំងអស់បានទេ?

ខ៖ អញ្ចឹងខ្ញុំបងគេ បន្ទាប់មកទីពីរឈ្មោះអៀ ទីបីឈ្មោះអន់ ទីបួនឈ្មោះវិបុល ហើយពៅគេឈ្មោះអឿន។

ក៖ ហើយសំរាប់បងស្រី បងស្រីមាននៅចាំទេថា
កាលនៅក្មេងៗបងស្រីចូលចិត្តធ្វើអ្វីខ្លះជាមួយបងប្អូនរបស់បងស្រី?

ខ៖ មិនដឹងជាចូលចិត្តអីទេ បើយើងជាកូនអ្នកស្រែ មានអីមានតែធ្វើការធម្មតាៗ។

ក៖ ហើយអញ្ចឹង បងស្រីមានធ្លាប់ទៅធ្វើស្រែ ទៅធ្វើអីជាមួយគ្នាទេ បងស្រី?

ខ៖ ហ្នឹងហើយ ទៅធ្វើស្រែ ដកស្ទូងជាមួយគ្នា មានតែប៉ុណ្ណោះ។

ក៖ ហើយអញ្ចឹង សំរាប់បងប្អូនរបស់បងស្រីសព្វថ្ងៃ គាត់រស់នៅណាខ្លះដែរបងស្រី?

ខ៖ ពួកគាត់សព្វថ្ងៃរស់នៅក្នុងភូមិនឹងជាមួយគ្នាទាំងអស់តើ។

ក៖ អូ! នៅជាមួយគ្នានៅនឹងទាំងអស់ហ៎! ហើយសំរាប់សព្វថ្ងៃនេះពួកគាត់ធ្វើការងារអ្វីខ្លះដែរ បងស្រី?

ខ៖ មានធ្វើអីទេ ពួកគាត់ទាំងអស់គ្នាធ្វើស្រែនឹង។

ក៖ ហើយអញ្ចឹង បងស្រីតើឪពុករបស់បងស្រី គាត់មានឈ្មោះអ្វីដែរ?

ខ៖ ឪពុករបស់ខ្ញុំគាត់ឈ្មោះតា សៅ។

ក៖ អូ! គាត់ឈ្មោះតាសៅហ៎! ហើយសំរាប់សព្វថ្ងៃនេះគាត់មានអាយុប៉ុន្មានហើយបងស្រី?

ខ៖ ខ្ញុំមិនចាំច្បាស់ទេ តែគាត់មានអាយុប្រហែលជា ហុកប្រាំបី ហុកប្រាំបួនឆ្នាំនឹង។

ក៖ ហើយអញ្ចឹង សំរាប់ម្តាយរបស់បងស្រី គាត់មានឈ្មោះអ្វីដែរ បងស្រី?

ខ៖ ម្តាយរបស់ខ្ញុំ ឈ្មោះ សូត្រ តែម។

កៈ ឈ្មោះសូត្រ តែម ហ៎បងស្រី! ហើយអញ្ចឹង សំរាប់សព្វថ្ងៃនេះម្តាយរបស់បងស្រី គាត់មានអាយុប៉ុន្មានហើយ បងស្រី?

ខៈ ម្តាយរបស់ខ្ញុំគាត់មានអាយុចិតសិបពីរឆ្នាំហើយ។

កៈ អូ! គាត់មានអាយុចិតសិបពីរឆ្នាំហើយ។ ហើយអញ្ចឹង តើម្តាយរបស់បងស្រីកើតនៅពេលណា បងស្រីនៅចាំទេ?

ខៈ ខ្ញុំអត់ចាំផង។

កៈ អូ! បងស្រីអត់ចាំទេ! ហើយអញ្ចឹង សព្វថ្ងៃនេះម្តាយរបស់បងស្រី រស់នៅភូមិជាមួយបងស្រីដែរ មែនទេ?

ខៈ នឹងហើយ នៅភូមិនឹងទាំងអស់តើ។

កៈ ហើយអញ្ចឹង សំរាប់ឪពុករបស់បងស្រី គាត់ជាមនុស្សដូចម្តេចដែរ?

ខៈ គាត់មានអី ធម្មតាៗដូចគេដូចឯងនឹង។

កៈ គាត់ជាមនុស្សស្លូតបូតឬក៏យ៉ាងម៉េចដែរបង?

ខៈ នឹងហើយ ឪពុករបស់ខ្ញុំស្លូតណាស់ មិនសូវមានមិនសូវរកអីទេ អ្នកណាធ្វើអីធ្វើទៅ។

កៈ អញ្ចឹងគាត់ស្លូតណាស់ចឹង! ហើយអញ្ចឹង សំរាប់ម្តាយរបស់បងស្រី គាត់ជាមនុស្សយ៉ាងម៉េចដែរ បងស្រី?

ខៈ ម្តាយរបស់ខ្ញុំដូចឪពុករបស់ខ្ញុំដែលនឹង គាត់ស្លូតបូត ចិត្តល្អ។

កៈ ហើយអញ្ចឹង បងស្រីមាននៅចាំពីខ្សែជីវិតរបស់ពួកគាត់កាលគាត់នៅពីក្មេងទេ?

ខៈ ខ្ញុំមិននៅចាំទេព្រោះអីខ្ញុំនៅក្មេងណាស់។

កៈ ហើយអញ្ចឹង បងស្រីធ្លាប់មានអនុស្សាវនីយ៍អីល្អៗជាមួយឪពុកម្តាយរបស់បងស្រីទេ?

ខៈ មាន ប៉ុន្តែវាថាវេទនាវាហួសពីវេទនាហើយពីជំនាន់ពលពតមកនឹង ធ្លាប់ស៊ីអត់ស៊ីឃ្លានលំបាក អស់ហើយជាមួយពួកគាត់នឹង។

កៈ ហើយអញ្ចឹង ឪពុកម្តាយរបស់បងស្រី
ពួកគាត់ធ្លាប់ប្រាប់បងស្រីពីខ្សែជីវិតរបស់គាត់កាលគាត់នៅក្មេងទេ?

ខៈ ពួកគាត់ធ្លាប់ប្រាប់តើ គាត់ប្រាប់ថាខ្សែជីវិតរបស់គាត់ពិបាកណាស់ មិនស្រួលទេពីក្មេងមកនឹង។

កៈ ហើយអញ្ចឹង សំរាប់បងស្រី បងស្រីមាននៅចាំឈ្មោះជីដូនជីតាខាងឪពុករបស់បងស្រីទេ?

ខ៖ នៅចាំតើ ជីដូនជីតាខាងឪពុកខ្ញុំឈ្មោះ តាភិន យាយឡាយ។

ក៖ ហើយចុះ បងស្រីមាននៅចាំឈ្មោះជីដូនជីតាខាងម្ដាយរបស់បងស្រីទេ?

ខ៖ ជីដូនជីតាខាងម្ដាយនឹង យាយរស់នៅរាល់ថ្ងៃនឹងឈ្មោះយាយត្រួន ហើយនឹង តាកែវ។

ក៖ ហើយអញ្ចឹង
សំរាប់ជីដូនជីតាខាងឪពុករបស់បងស្រីពួកគាត់កើតនៅពេលណាបងស្រីនៅចាំទេ?

ខ៖ អូ! បើសួរខ្ញុំចប់បណ្ដោយ មិនចាំសោះតែម្ដង ព្រោះអីនៅក្មេងពេកអត់ដឹងអីទេ។

ក៖ ហើយចុះ សំរាប់ជីដូនជីតាខាងម្ដាយរបស់បងស្រី ពួកគាត់កើតនៅពេលណាបងស្រីនៅចាំទេ?

ខ៖ អត់ចាំទេ តែគ្រាន់តែដឹងថាយាយសព្វថ្ងៃអាយុកៅសិបឆ្នាំហើយ តែគាត់កើតនៅពេលណា
អត់ដឹងទេ ព្រោះអីពីបីជំនាន់ហើយនឹង។

ក៖ អូ! អញ្ចឹងយាយខាងម្ដាយរបស់បងស្រីគាត់មានអាយុកៅសិបឆ្នាំហើយ។ ហើយចឹង
យាយខាងម្ដាយរបស់បងស្រីគាត់នៅរស់រាល់ថ្ងៃនឹង?

ខ៖ ចា៎! គាត់រស់នៅរាល់ថ្ងៃនឹង គាត់នៅលើផ្ទះ គ្រាន់តែគាត់មិនអាចដើរបាន។

ក៖ ហើយចុះសំរាប់តារបស់បងស្រីខាងម្ដាយ គាត់នៅរស់ដែរឬទេ?

ខ៖ តារបស់ខ្ញុំកាលជំនាន់ពលពតគេវាយចោលបាត់ហើយ។

ក៖ អូ! ពលពតវាយគាត់ចោលបាត់ហើយហ៎បងស្រី។ ហើយអញ្ចឹង
សំរាប់ជីដូនជីតារបស់បងស្រីខាងឪពុកវិញតើសព្វនេះពួកគាត់នៅរស់ដែរឬទេបង?

ខ៖ ជីដូនជីតារបស់ខ្ញុំខាងឪពុកត្រូវពួកពលពតវាយសំលាប់អត់ហើយ។

ក៖ អូ! ត្រូវពួកពលពតសំលាប់អស់ហើយ។ ហើយអញ្ចឹង
ពួកគាត់ស្លាប់អស់រយៈពេលប៉ុន្មានឆ្នាំហើយ?

ខ៖ ពេលមកពីអាពតវិញ នៅពេលដែលគេកៀរមកវិញគាត់ត្រូវបានគេសំលាប់ចោលអស់តែម្ដង
ប្រហែលជាសាមសិបឆ្នាំ ជិតសែសិបឆ្នាំហើយ។

ក៖ ហើយអញ្ចឹងសំរាប់ឪពុករបស់បងស្រីគាត់ធ្លាប់ប្រាប់បងពី ជីវិតរបស់ជីដូនជីតារបស់បងស្រី
កាលពួកគាត់នៅក្មេងៗទេ?

ខ៖ គាត់មិនដែលប្រាប់ផង។

ក៖ ហើយអញ្ចឹង សំរាប់បងស្រី
ហើយនឹងក្រុមគ្រួសារបានរស់នៅក្នុងខេត្តនេះអស់រយៈពេលប៉ុន្មានឆ្នាំហើយ?

ខ៖ មករស់នៅទីនេះតាំងពីចេញមកពីអាពតវិញ សាមសិបជិតសែសិបឆ្នាំហើយ។

ក៖ អញ្ចឹងមានន័យពេលដែលចេញពីអាពតជំនាន់ឆ្នាំចិតសិបប្រាំបួននឹង
គឺនាំគ្នាមករស់នៅក្នុងភូមិនេះតែម្តង។

ខ៖ នឹងហើយ ពេលមកពីជំនាន់អាពតមក មករស់នៅនឹងតែម្តង។

ក៖ ហើយអញ្ចឹង បងស្រីមានដូចជាសាច់ញាត្តិដែលរស់នៅក្រៅប្រទេសកម្ពុជាយើងទេ?

ខ៖ មិនមានទេ គ្មាននរណានៅទេ បងប្អូនមានតែនៅក្នុងភូមិយើងនឹងទេ។

ក៖ អូ! អញ្ចឹងគ្មានទេន៎បងស្រី។ ហើយអញ្ចឹង សំរាប់បងស្រីបានរៀបអាពាហ៍ពិពាហ៍ហើយឬនៅ?

ខ៖ ខ្ញុំបានរៀបអាពាហ៍ពិពាហ៍រួចហើយ។

ក៖ ហើយអញ្ចឹង សំរាប់ស្វាមីរបស់បងស្រីគាត់មានឈ្មោះអ្វីដែរ បងស្រី?

ខ៖ ស្វាមីរបស់ខ្ញុំ គាត់ឈ្មោះតុង។

ក៖ បងប្រុសតុង! ហើយអញ្ចឹង បងស្រីមាននៅចាំទេថា ពេលដែលបងស្រីបានរៀបអាពាហ៍ពិពាហ៍
តើបងស្រីមានអាយុប៉ុន្មានហើយ?

ខ៖ ពេលដែលខ្ញុំបានរៀបអាពាហ៍ពិពាហ៍មានអាយុប្រហែលជាសាមសិបជាង។

ក៖ ហើយអញ្ចឹង តើបងបានរៀបអាពាហ៍ពិពាហ៍នឹងពេលណា បងស្រីមាននៅចាំទេ?

ខ៖ ខ្ញុំអត់ចាំទេ តែគ្រាន់តែចាំថាពេលដែលបានរៀបអាពាហ៍ពិពាហ៍នឹងមានអាយុសាមសិបជាង។

ក៖ ហើយអញ្ចឹង កាលបងស្រីរៀបអាពាហ៍ពិពាហ៍នឹង បងអាយុប្រហែលជាសាម ប៉ុន្មាន?

ខ៖ ស្មានមិនត្រូវទេ ភ្លេចហើយព្រោះយូរហើយនឹង។

ក៖ ហើយអញ្ចឹង សំរាប់អាពាហ៍ពិពាហ៍នឹងរៀបចំឡើងដោយឪពុកម្តាយ
ឬបងស្រីរៀបចំឡើងដោយខ្លួនឯង?

ខ៖ ឪពុកម្តាយរបស់ខ្ញុំជាអ្នករៀបចំអោយ។

ក៖ ហើយអញ្ចឹង ពេលដែលរៀបអាពាហ៍ពិពាហ៍នឹង ពេលដែលខាងបងប្រុសចូលមកស្តីដណ្តឹងបង
នឹងមានដូចជាថ្លៃជំនួនទេបងស្រី?

ខ៖ មានដែលតែតិចតួចណាស់។

ក៖ ហើយអញ្ចឹង តើបងស្រីអាចជួយប្រាប់
ពេលដែលបងស្រីហើយនឹងបងប្រុសបានជួបគ្នាជាលើកដំបូងបានទេ?

ខ៖ មិនចាំទេ ព្រោះអីយូរហើយនឹង។

ក៖ អូ! អញ្ចឹងភ្លេចហើយបងស្រី។
ហើយអញ្ចឹងសំរាប់ចំណងអាពាហ៍ពិពាហ៍របស់បងស្រីជាមួយបងប្រុស មានកូនប៉ុន្មាននាក់ដែរ?

ខ៖ អត់មានកូនទេ។

ក៖ អូ! អត់មានកូនទេ។ ហើយអញ្ចឹង សំរាប់បងស្រី ចេះអាន និងសរសេរអក្សរខ្មែរដែរឬទេ?

ខ៖ មិនចេះទេ។

ក៖ មិនចេះទេ! ហើយអញ្ចឹង បងស្រីចេះនិយាយភាសាផ្សេងក្រៅពីភាសាខ្មែរទេ?

ខ៖ មិនចេះទេ។

ក៖ ហើយអញ្ចឹង បងស្រីរៀនបានដល់ថ្នាក់ទីប៉ុន្មានដែរ?

ខ៖ ពេលមកពីសម័យពលពតបានរៀនតិចតួច មែនថាមិនចេះទេ ចេះដែរ
ប៉ុន្តែដូចថាយើងទៅរកស៊ីជាមួយម៉ែឪនៅឆ្ងាយ អញ្ចឹងហើយមិនបាននៅរៀនជាប់នឹងគេទេ
ទៅតាមម៉ែឪទៅរកស៊ីនៅស្រុកលើ ទៅកាប់ឈើកាប់អីនឹង មិនសូវជាបានរៀនជាប់លាប់នឹងគេទេ
ចឹងចេះដែរ តែចេះបានតិចតួច  នឹង។

ក៖ អញ្ចឹង បងស្រីបានចូលសាលារៀនខ្លះដែរ មែនទេបងស្រី?

ខ៖ បានចូល តែគ្រាន់ថាយើងវាមិនចេះដោយសារតែយើងដើរលិចដើរកើត
មិនបាននៅរៀនអោយជាប់លាប់នឹងគេ។

ក៖ ហើយអញ្ចឹង កាលនោះបងបានរៀនដល់ថ្នាក់ទីប៉ុន្មានដែរ បងស្រី?

ខ៖ កាលនោះខ្ញុំបានរៀនដល់ថ្នាក់ទី២។

ក៖ អូ! បងរៀនបានត្រឹមថ្នាក់ទី២ហ៎! ហើយអញ្ចឹងតើបងរៀននៅសាលាណាដែរបងស្រី?

ខ៖ ខ្ញុំរៀននៅសាលាវត្តដំរិល នឹងណា។

ក៖ អញ្ចឹងគេហៅឈ្មោះសាលាវត្តដំរិលតែម្តងបង?

ខ៖ ចា៎!

ក៖ ហើយអញ្ចឹង តើបងស្រីធ្លាប់មានមិត្តភក្តិដែលធំធាត់មកជាមួយគ្នាកាលដែលនៅក្មេងទេ?

ខ៖ មានច្រើនកាលនៅក្មេងៗ តែលូវគេចេញទៅរកស៊ីអស់ហើយ នៅសល់តែប៉ុន្មាននាក់ទេ។

ក៖ ហើយអញ្ចឹង បងស្រីអាចជួយរៀបរាប់ឈ្មោះរបស់គាត់ម្នាក់ពីនាក់បានទេបងស្រី?

ខ៖ មានឈ្មោះ យ៉ា ឈ្មោះធី និងឈ្មោះថា ហើយនឹងមីងរាល់ថ្ងៃនឹង មីងហឿន មីងអីនឹង។

ក៖ ហើយអញ្ចឹង សំរាប់មិត្តភក្តិរបស់បងស្រី សព្វថ្ងៃនេះគាត់មានអាយុប្រហែលប៉ុន្មានឆ្នាំដែរ?

ខ៖ ពួកគាត់មានអាយុប្រហាក់ប្រហែលនឹងខ្ញុំដែលនឹង។

ក៖ ហើយអញ្ចឹង សំរាប់កាលពេលនៅក្មេងៗ
តើបងស្រីចូលចិត្តធ្វើអ្វីខ្លះជាមួយមិត្តភក្តិជិតរបស់បងស្រី?

ខ៖ គ្មានធ្វើអីទេ មានតែទៅធ្វើអីជាមួយគ្នា ជួយគ្នាទៅវិញទៅមក ហើយទៅរកស៊ីជាមួយគ្នា ហើយមកវិញទៅធ្វើស្រែទៅ។

ក៖ ហ្នឹងហើយ ធ្វើស្រែធ្វើចំការជាមួយគ្នា ហើយបងស្រីធ្លាប់ដូចជា
ខែចូលឆ្នាំចូលអីនាំគ្នាទៅលេងល្បែងប្រជាប្រិយខ្មែរជាមួយគ្នាទេបង?

ខ៖ ធ្លាប់មានតើ។

ក៖ ហើយអញ្ចឹង ពេលដែលបងទៅលេងជាមួយមិត្តភក្តិចឹង
តើបងមានអារម្មណ៍ដូចម្តេចដែរបងស្រី?

ខ៖ មានអីសប្បាយរីករាយ។

ក៖ ហ្នឹងហើយ! ខ្ញុំធ្លាប់ដែលតើបង ពេលខែចូលឆ្នាំនាំមិត្តភក្តិទៅលេងល្បែប្រជាប្រិយ
មានអារម្មណ៍ល្អហើយមានភាពស្និតស្នាលថែមទៀត។ ហើយអញ្ចឹង សំរាប់បងស្រីសព្វថ្ងៃនេះ
បងស្រីមានធ្វើស្រែចំការទេ?

ខ៖ មានធ្វើតើ ធ្វើស្រែរាល់តែឆ្នាំនឹង បើមិនធ្វើបានអីហូប។

ក៖ ហើយអញ្ចឹង សំរាប់បងស្រីក្រៅពីធ្វើស្រែ តើបងស្រីមានប្រកបមុខរបរអ្វីផ្សេងទៀតទេបងស្រី?

ខ៖ អត់មានទេ ធ្វើតែស្រែនឹង។

ក៖ ហើយអញ្ចឹង សំរាប់បងស្រីផ្ទាល់ គិតថាជីវិតរបស់បងស្រីតាំងពីក្មេងរហូតមកដល់ពេលនេះ
តើជីវិតរបស់បងស្រីមានការផ្លាស់ប្តូរដែរឬទេ?

ខ៖ មានការផ្លាស់ប្តូរតើ។

ក៖ តើជីវិតរបស់បងស្រីមានការផ្លាស់ប្តូរអ្វីខ្លះបងស្រី?

ខ៖ ផ្លាស់ប្តូរថាចិត្តនឹងវាចេះគិតច្រើនជាងមុន មិនដូចពីក្មេងទេ។

ក៖ អូ! អញ្ចឹងមានន័យថាយើងចេះគិតច្រើនជាងមុន។ ហើយអញ្ចឹង សំរាប់ម្ហូបវិញ
តើបងស្រីចូលចិត្តហូបម្ហូបអ្វីជាងគេបងស្រី?

ខ៖ ធម្មតា ចូលចិត្តញាំទាំងអស់ ម្ហូបអីក៏ញាំបានដែរមិនប្រកាន់ទ្បើយ។

ក៖ ហើយអញ្ចឹង សំរាប់ល្បែងប្រជាប្រិយខ្មែរដូចជា បោះឈូង បោះអង្គុញ់ ទាញព្រ័ត្រ តើបងស្រីចូលចិត្តលេងទេ តាំងពីក្មេងមក?

ខ៖ ចូលចិត្តលេង តែមិនមែនជាអ្នកដែលចូលចិត្តរាំវែកអីនឹងគេទេ។

ក៖ ហើយអញ្ចឹង សំរាប់ល្បែងប្រជាប្រិយខ្មែរ តើបងស្រីចូលចិត្តលេងល្បែងអ្វីខ្លះបងស្រី?

ខ៖ មិនដឹងចូលចិត្តអ្វីទេ បើឥឡូវមិនដែលលេងផង លេងតែកាលនៅក្មេង ភ្លេចអស់ហើយ។

ក៖ ហើយអញ្ចឹង សំរាប់បទចម្រៀង តើមានបទចម្រៀងណាខ្លះដែលបងស្រីចូលចិត្តស្តាប់ ហើយរៀនច្រៀងតាមតាំងពីក្មេងមក?

ខ៖ មិនដែលចេះច្រៀងផង មិនដឹងច្រៀងតាមថាមិចទេ ប៉ុន្តែចូលចិត្តស្តាប់ បទចម្រៀងចំរុះ មិនថាបទពីដើម ឬបទសម័យទេចូលចិត្តតែទាំងអស់នឹង។

ក៖ ហើយអញ្ចឹង សំរាប់ក្រុមគ្រួសាររបស់បងស្រី មាននរណាដែលគាត់ចេះលេងឧបករណ៍ភ្លេងដែរឬទេបងស្រី?

ខ៖ ក្នុងក្រុមគ្រួសាររបស់ខ្ញុំគ្មាននរណាចេះលេងភ្លេងទេ។

ក៖ ហើយអញ្ចឹង តើផ្ទះបងស្រីមានលក្ខណ:ដូចម្តេចកាលបងស្រីនៅក្មេង?

ខ៖ ផ្ទះនឹងមិនធំទេ ផ្ទះតូចធម្មតានឹង គ្រាន់តែយើងមើលទៅមិនអាក្រក់ពេក តែក៏វាមិនល្អណាស់ណាទេ។

ក៖ ហើយអញ្ចឹង សំរាប់ផ្ទះនឹង បងស្រីធ្វើខ្លួនឯង ឬមួយបងស្រីបានជួលគេអោយធ្វើអោយ?

ខ៖ ផ្ទះនឹងធ្វើខ្លួនឯង។

ក៖ ហើយសំរាប់ផ្ទះនឹង សំភារ:ដែលសំរាប់ធ្វើផ្ទះមួយនឹង តើបងស្រីបានមកពីណាដែលបងស្រីយើងទិញគេ ឬមួយយើងទៅរកដោយខ្លួនឯង ដោយដើរកាប់នៅក្នុងព្រៃ?

ខ៖ ឥឡូវនឹងទិញតើ។

ក៖ ហើយអញ្ចឹង បងស្រីអាចជួយប្រាប់បានទេ ថាសំភារ:សំរាប់ធ្វើផ្ទះនឹងមានអ្វីខ្លះបងស្រី?

ខ៖ មានឈើមានដែកគោល មានក្បឿង ដែកគាស់ មានខ្សាច់ មានស៊ីម៉ង់ត៍ មានថ្ម រួមគ្នាទាំងអស់។

ក៖ រួមគ្នាទើបយើងអាចធ្វើបានជាផ្ទះនៅន់បង! ហើយអញ្ចឹង តើនរណាជាអ្នកប្រាប់បងស្រីអោយធ្វើផ្ទះមួយនឹង ឬមួយបងចេះដោយខ្លួនឯងតែម្តង?

ខ៖ ដូចថា យើងចង់បានម៉ូតណាចឹង យើងគិតដោយខ្លួនឯង ថាយើងធ្វើអានេះមួយអានោះមួយទៅ ដើម្បីអោយវាចេញជាម៉ូតដែលយើងចង់បាន។

ក៖ ហើយអញ្ចឹង បងស្រីមានជំនាញដែលបន្តវេនពីក្រុមគ្រួសារទេ ដូចជាវេញវល្លិ៍ផ្ដៅ ត្បាញកន្ទេល ឬក៏ជំនាញធ្វើស្ករត្នោតអីចឹង?

ខ៖ មិនចេះទេ នៅក្នុងគ្រួសារខ្ញុំគ្មាននរណាចេះផង។

ក៖ អូ! អញ្ចឹងអត់ចេះទេបងស្រី។ ហើយអញ្ចឹង បងស្រីគិតថា ជីវិតរបស់បងស្រី មានពេលដែលលំបាកជាងគេទេបងស្រី?

ខ៖ មាន។

ក៖ ហើយអញ្ចឹង ពេលណាដែលបានគិតថាជាពេលដែលលំបាកជាងគេនោះ? ហើយបងស្រីបានឆ្លងកាត់ពេលដែលលំបាកនឹងដោយរបៀបណាដែរ?

ខ៖ ពេលដែលខំរកនឹងគេហើយតែវាមិនមានសោះ ប្រឹងរកណាស់ ទៅណេះទៅណោះហើយ ចេះតែដើររកហើយ តែនៅតែមិនបានមាននឹងគេ។

ក៖ អញ្ចឹងហ៎! អត់បានជួបអ្វីដែលល្អៗសោះ។ ហើយអញ្ចឹង ជាចុងក្រោយបើសិនជាបងចង់ផ្ដាំផ្ញើរ ទៅកូនចៅជំនាន់ក្រោយ តើបងស្រីនឹងផ្ដាំផ្ញើរអ្វីខ្លះទៅកាន់ពួកគាត់?

ខ៖ ខ្ញុំគ្រាន់តែផ្ដាំផ្ញើរទៅកាន់ក្មេងជំនាន់ក្រោយថា អោយចេះប្រឹងប្រែង ចេះតស៊ូឡើងក្នុងជីវិតយើង នេះតាំងពីសម័យពលពតមកពិបាកណាស់។

ក៖ ហើយអញ្ចឹង បើសិនជាបងស្រីចង់អោយកូនចៅជំនាន់ក្រោយរបស់បងស្រីជៀសវាង តើបងស្រីចង់អោយពួកគាត់ចៀសវាងពីអ្វីដែរ?

ខ៖
ខ្ញុំចង់កូនចៅជំនាន់ចជៀសអោយផុតពីបញ្ហាអាក្រក់នឹងដូចគ្រឿងញៀនកុំអោយយកមកដាក់នៅនឹងខ្លួន ហើយម៉ូតូក៏ដោយកុំអោយបើកលើសល្បឿនហួសពីសមត្ថភាពរបស់យើង។

ក៖ ហើយជាចុងក្រោយ ខ្ញុំសុំថ្លែងអំណរគុណសំរាប់បងស្រីដែលបានចំណាយពេលវេលាដើម្បី អោយខ្ញុំអាចសម្ភាសន៍ពីជីវប្រវត្តិរបស់បងស្រី ហើយខ្ញុំសូមជូនពរដល់បងស្រី សូមអោយបងស្រីមានសុខភាពល្អ ហើយសូមអោយជោគជ័យគ្រប់មុខរបររកស៊ី ដូចជាស្រែចំការធ្វើទៅបានទទួលផលល្អ ហើយខ្ញុំសង្ឃឹមថាបទសម្ភាសន៍មួយនេះ អំពីខ្សែជីវិតរបស់បងស្រីនឹងអាចជួយដល់ក្មេងៗជំនាន់ក្រោយពួកគាត់រៀន ហើយពួកគាត់អាចមានភាពតស៊ូ ដើម្បីអោយពួកគាត់គិតថា ពួកគាត់ពិតជាលំបាក តែពួកគាត់នៅតែខំប្រឹងហើយនឹងយកឈ្នះលើភាពលំបាកទាំងអស់នឹង។ អរគុណច្រើនហើយបងស្រី។